# I-ខុទ្ទកាល័យព្រះមហាក្សត្រ

## ១-ព្រះរាជក្រម

ព្រះរាជក្រម នស/រកម/១០០០/០៨

យើង

ព្រះបាទសម្ដេច ព្រះនរោត្ដម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-តាមសេចក្ដីក្រាបបង្គំទូលថ្វាយ អំពីសម្ដេចនាយករដ្ឋមន្ត្រី និងអំពីឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

### ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងសន្ធិសញ្ញា ស្ដីពីការហាមឃាត់ជាទូទៅនៃការសាកល្បងអាវុធនុយក្លេអ៊ែរ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០០ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី១ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅ ៖

Downloaded from http://www.khmerlaws.com

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមអោយព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុង សន្ធិសញ្ញាស្តីពីការហាមឃាត់ជាទូទៅ នៃការសាកល្បងអាវុធនុយក្លេអ៊ែរ

**មាត្រា ១ .-**

អនុម័តអោយព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងសន្ធិសញ្ញា ស្តីពីការហាមឃាត់ជាទូទៅនៃការសាកល្បងអាវុធនុយក្លេអ៊ែរ ដែលបានចុះហត្ថលេខានៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៦ ក្នុងឱកាសមហាសន្និបាតនៃអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក ។

**មាត្រា ២ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញរាល់នីតិវិធី ដើម្បីអនុវត្តសន្ធិសញ្ញានេះ ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ តុលា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានយកជម្រាប សម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិស្តីទី
ហត្ថលេខា
អ៊ុច គឹមអន

★★★

Downloaded from http://www.khmerlaws.com